**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

*ថ្ងៃ ពុធ ៨រោច ខែ ទុតិយាសាឍ ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧*
*រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០២៣*

# សេចក្តីជូនដំណឹងសម្រាប់សារព័ត៌មាន
# ស្តីពីជំនួបសម្តែងការគួរសម និងការជម្រាបលារបស់លោក Yasuhisa Ojima
# ប្រធានស្ថានតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា

នាព្រឹកថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០២៣, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសម ក្នុងខណៈដែលលោក **Yasuhisa Ojima** ប្រធានស្ថានតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា ជម្រាបលា ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ឧបនាយករដ្ឋមន្ត្រី បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះកិច្ចខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្តរបស់លោក **Yasuhisa Ojima** ដែលបានបំពេញភារកិច្ចរបស់ខ្លួនក្នុងនាមជាតំណាងមូលនិធិរូបិយវត្ថុអន្តរជាតិប្រចាំកម្ពុជា ក្នុងរយៈពេល ៤ ឆ្នាំកន្លងមក ។ ក្រោមការដឹកនាំរបស់លោក **Yasuhisa Ojima**, មូលនិធិរូបិយវត្ថុអន្តរជាតិបានផ្តល់ការគាំទ្រដល់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងការបន្តតាមដាន និងវាយតម្លៃស្ថានភាពសេដ្ឋកិច្ចកម្ពុជា, ការបណ្តុះបណ្តាលដល់មន្ត្រីជំនាញរបស់ក្រសួង និងការផ្តល់ជំនួយបច្ចេកទេសដល់អគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួង ដូចជា ការពង្រឹងម៉ូដែលព្យាករណ៍សេដ្ឋកិច្ច, ការរៀបចំស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល, ការពិនិត្យឡើងវិញលើច្បាប់ស្តីពីគយ, ព្រមទាំងវិធានការកែទម្រង់របស់រាជរដ្ឋាភិបាលមួយចំនួនទៀត ពិសេស ការគាំទ្រដល់វិទ្យាស្ថានស្ថិតិក្នុងការរៀបចំ ផ.ស.ស ឆ្នាំគោលថ្មី ជាដើម ។ ទន្ទឹមនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានស្នើសុំឱ្យមូលនិធិរូបិយវត្ថុអន្តរជាតិ ជួយពិនិត្យឡើងវិញលើក្របខណ្ឌ និងយន្តការនៃការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយនិរន្តរភាព ព្រមទាំងបន្តគាំទ្រជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលដល់មន្ត្រីជំនាញ ដើម្បីបន្តអភិវឌ្ឍមូលធនមនុស្ស និងការពង្រឹងសមត្ថភាពស្ថាប័នរបស់ក្រសួង ។

លោក **Yasuhisa Ojima** បានថ្លែងអំណរគុណចំពោះកិច្ចសហការយ៉ាងល្អប្រសើរជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកន្លងមក និងអបអរសាទរកម្ពុជាដែលបានគ្រប់គ្រងសេដ្ឋកិច្ចបានល្អ ទោះបីជាឆ្លងកាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងបញ្ហាប្រឈមនានាក្នុងតំបន់និងសកល ។ ទន្ទឹមនេះ, លោកនឹងបន្តជំរុញការគាំទ្របច្ចេកទេសដល់ប្រទេសកម្ពុជា ពិសេស ការស្នើសុំថ្មីរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ។

ជាកិច្ចបញ្ចប់, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី ក៏បានជូនពរ ជាថ្មីម្តងទៀត ជូនលោក **Yasuhisa Ojima** ទទួលបានជោគជ័យគ្រប់ភារកិច្ច និងរង់ចាំស្វាគមន៍បេសកកម្មរបស់ក្រុមការងារមូលនិធិរូបិយវត្ថុអន្តរជាតិនាពេល ខាងមុខ ៕